# វិបត្តិ ?



## វិបត្តិ ?

សង្គមខ្មែរបច្ចុប្បន្ន ជួបប្រទះ នូវ វិបត្តិគ្រប់បែបយ៉ាង ទោះបីវាមាន ភាពក្រៅ ជា សង្គម មាន ការរីកចំរើន តាមជំហានយឺតតែ អង្គុក[1]។ ទស្សនៈ នៃ បដិវាទកម្ម[2] នេះ នាំឲមានការពិភាក្សា រវាង ខ្មែរនឹងខ្មែរ មានលក្ខណ:ហិង្សា ព្រោះ វិបត្តិខ្មែរ វាតម្រួតគ្នា នូវ វិបត្តិសង្គម,វិបត្តិនយោបាយ ហើយនឹង វិបត្តិ នៃ អធិបតេយ្យភាពជាតិ។ វិបត្តិ ទាំងឡាយនេះ ជា កំណួតបិទមុខពិបាកនឹងស្រាយវា ព្រោះ មុខខ្មែរ វាពុក ប៉ះកាលណា វាផុយចាប់លែងបាន។ នៅក្នុង ស្ថានភាព បែបនេះ នាំចោទជាចំណោទ នៃ កំណែទំរង់ ថា តើ ត្រូវ ចាប់ផ្ដើមកែវា ពីចំណុចណាមុន ? ធ្វើកំណែទំរង់ នូវ ចិត្តគំនិត (esprit) ជា បឋម ? ឬ ស្ថាប័នជាតិ ជាដំបូងសិន ? ឬ ធ្វើរួមគ្នាតែម្ដង ?

ការរស់នៅ ជាទូទៅ សព្វថ្ងៃ របស់ខ្មែរយើង ដែលនៅមានជំនឿ ថា មាន ជីវិតអារ្យៈ តែក្បៀយនេះ អនារ្យធម៌ (barbarie) ហួងចូលក្នុងចិត្តគំនិតយើងដោយមិនដឹងខ្លួន នូវ គុណវិបត្តិ គ្រប់បែបយ៉ាង ដូចយ៉ាង អត្តទត្តភាព, តម្រេក, ពិភល, ការមាក់ងាយ, ក្រែវក្រោធ និង ទោសៈ ដែលជា គុណវិបត្តិ នាំ

[1] អង្គុក ; un pas régulier។
[2] ទស្សនៈ នៃ បដិវាទកម្ម ; conception de contradiction។

## វិបត្តិ ?

បន្ទូត និង បំពុល ឋានៈជីវិត គួរអោយអាណោចអាធម្ម ហើយ ផាញ៉ីកញយ មានវិបត្តិភ័យ ក្នុង អាស្រ័យការទាក់ទង រវាង បុគ្គលនឹងបុគ្គល, ភេទនឹងភេទ, វណ្ណៈនឹងវណ្ណៈ និង ប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ។ ភាពមោហ៍ប៉ាំង ក្នុងអត្តចិត្ត និង ទៅលើអ្នកដទៃ វាទៅជា បាតុភូត រាល់ថ្ងៃ សំរាប់ ការរស់នៅ ដែលវាអាចនាំអោយ ភាព អមនុស្សធម៌ និង អនារ្យធម៌ ផុសចេញ គ្រប់ពេលវេលា ពីក្នុងចិត្តគំនិត នៃ នរអារ្យៈ (humain civilisé)។ ការផុសចេញ នៃ គុណវិបត្តិនេះ វានាំលុប នូវ គុណសម្បត្តិ នៃ នរអារ្យៈ ដូចយ៉ាង ករុណា, ភាតរភាព, ការញ្ញភាព (pardon) នៃ សាសនា និង ករុញ្ញចិត្ត នៃ អ្នកមនុស្សនិយម។

អភិវឌ្ឍន៏សព្វថ្ងៃ ដែលសន្យាថា ផ្តល់នូវ សុភមង្គល ក្នុង សុខុមាលភាព បែរជា បំផុះ នូវ ទុក្ខាភាព (mal-être) ក្នុង សុខុមាលភាព នៃ សម្ភារៈ ព្រោះ វាមិនអាចឲមាន ការរស់នៅ ក្នុង សេចក្តីរីករាយ (bien-vivre) បាននោះឡើយ។ ទ្រនិចបង្ហាញ (indicateur) នូវ ឋានៈនៃការអប់រំ និង លក្ខខណ្ឌ នៃអនាម័យ វាមិនបានដឹងថា សញ្ញាប័ត្រ និង ការឈប់ធ្វើការ ដោយមានជម្ងឺ វាអាច សមិតនឹង ទុក្ខាភាព និង ជម្ងឺធ្លាក់ទឹកចិត្ត បានយ៉ាងងាយ។ ដូច្នេះ សុខុមាលភាព និង ទុក្ខាភាព គេមិនអាចគននា នៅត្រឹមតែ ឋានៈ នៃ ភោគសម្បត្តិ តិចច្រើន នោះឡើយ ព្រោះ មហាសេដ្ឋី អាចជាជន ទុក្ខាភាព រីឯ កសិករ វិញ អាចជាជន មាន សុភមង្គល ក្នុង សុខាមាលភាព ព្រោះថា សុភមង្គល វាជា អត្តតម្លៃ របស់ បុគ្គលម្នាក់ៗ គឺថា រៀងៗខ្លួន

## វិបត្តិ ?

មាន ការយល់ ខុសៗគ្នា អំពី ការចាំបាច់ សំរាប់ សុភមង្គល។ ការរស់នៅក្នុងសេចក្តីរីករាយ គឺឲតម្លៃទៅលើ គុណភាព ជាង បរិមាណ (ចំនួន), មនុស្សមានកិត្តិយស មានតម្លៃជាង មនុស្សមានភាពសម្បូណ៍, សេចក្តីត្រូវការ នៃ ស្វ័យភាព និង សេចក្តីត្រូវការ នៃ សហគម ត្រូវ រាប់រងគ្នា ជា ចាំបាច់, ពាក្យកាព្យឃ្លោង នៃ ជីវិត ត្រូវទុកជា ពាក្យទីមួយ នៃ សេចក្តីស្នេហា, ព្រោះថា វិសិដ្ឋភាព ទាំងឡាយ នេះ វាជា បរមត្ថ (vérité suprême) នៃ មនុស្សលោក។

លើសអំពី អភិវឌ្ឍន៏ ត្រូវចាំបាច់ មាន នយោបាយ នៃ មនុស្សជាតិ ជា មូលដ្ឋាន នៃ ការដឹកនាំមនុស្ស។ សន្តិភាព តម្រូវតាមការចង់បាន នៃ អំណាច នាំបំផុះ នូវ អយុត្តិធម៏ និង អំណាចផ្តាច់ការ។ ការដឹកនាំមនុស្ស គឺ ការរកដំណោះស្រាយ នៃ បញ្ហាមនុស្សអាត្មា និង មនុស្សសង្គម ដូច្នេះ ត្រូវដាំស្តំ សន្តិភាពឲជាប់ នៅក្នុងសង្គម តែជា សន្តិភាព តម្រូវតាមឧត្តមគតិ នៃ លទ្ធិប្រជាធិបតេយ្យ ដែលវាអាច បង្កើតឲបានច្រើនឡើង នូវអ្វីជាបវរ តួយ៉ាង៖ ប្រពៃណី នៃ មនុស្សនិយម, គំនិតរិះគន់ និង គំនិតស្វ័យទិតៀន, គោលការណ៏ នៃ លទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស។ សន្តិភាព សំរាប់ ប្រជាពលរដ្ឋ ត្រូវមានមុខងារប្រឆាំងនឹង អនុភាព អវិជ្ជមាន គ្រប់បែបយ៉ាង មានកើតឡើង នៅក្នុងសង្គម ដោយ បង្កើន អនុភាព វិជ្ជមាន។ បញ្ហាជម្រៅ របស់សង្គម គឺ ការបង្កើន នៃ មេដំបែ សំរាប់ បំផ្លាញខ្លួនឯង ដែលគេឲឈ្មោះថា អកុសល នៃ អរិយធម៏ថ្មី (nouveau

# វិបត្តិ ?

mal de civilisation)។ ឧទាហរណ៍ ដូចជា ការលែងលះគ្នា រវាង ប្រាណ និង ព្រលឹង នៃ សង្គម ឬ ព្រលឹង រត់គេចខ្លួនពី ប្រាណ។ ការធ្វើអភិវឌ្ឍន៍ តែ សម្ភារៈ ដូចយ៉ាង កសាង អាគារ ស្ពឹមស្ពៃ តាមទីក្រុង តែជាទីកន្លែង គ្មានព្រលឹង សំរាប់បន្ថយ គម្លាត រវាង អ្នកមាន និង អ្នកក្រ គឺ ច្បាស់ជាបង្កើន នូវ ចោរកម្ម, គ្រឿងញៀន, ឧក្រិដ្ឋកម្ម និង អំពើអយុត្តិធម៌ គ្រប់បែបយ៉ាង។

វិសមភាព រវាង អ្នកមាន និង អ្នកក្រ មានគ្រប់លក្ខណៈ ដូចយ៉ាង ផែនដី (ទីក្រុង/ជនបទ), សេដ្ឋកិច្ច (អ្នកមាន ហួសប្រមាណ/អ្នកក្រ ក្ររហាម), សង្គម (របបជីវិត), អនាម័យ (វិសមភាពហួសប្រមាណ រវាង អ្នកមាន និង អ្នកក្រ) និង វប្បធម៌ (បញ្ហា សិទ្ធិ នៃ ការសិក្សា)។ ជម្រៅ នៃ វិសមភាព គឺ ព្រហ្មលិខិត រវាង អ្នក រងគ្រោះ នៃ ជីវិតខ្លួន ព្រោះ មានកំណើត ក្នុង គ្រួសារ ក្រតោកយ៉ាក និង អ្នក អាស្រ័យផលអស្ចារ្យ នៃ ជីវិតខ្លួន ព្រោះ មានកំណើត ក្នុង គ្រួសារ មានទ្រព្យ។ ទោះបីដឹកថា ការមានទ្រព្យច្រើន វាមិនពិត អាចផ្តល់ សុភមង្គល ដល់អាត្មា តែ ទុគតិភាព វា ច្បាស់ជា បង្កើត គ្រោះអាក្រក់ពិត ដល់ជីវិត។ ដូច្នេះក្នុងសង្គមត្រូវមាន នយោបាយ នៃ មនុស្សជាតិ ដើម្បី ទប់ ព្រហ្មលិខិត កុំឲវាក្លាយទៅជា កម្មវាសនាគេចមិនផុត សំរាប់ វណ្ណៈអ្នកក្រពីកំណើត។ ពិតណាស់ហើយថា នៅក្នុងសង្គមនិមួយៗ វាតែងតែមាន អ្នកមាន និង អ្នកក្រ តែនៅក្នុង សង្គមមនុស្សនិយម គឺ នយោបាយ នៃ មនុស្សជាតិ នេះហើយ ដែលមានតួនាទីធំចម្បង សំរាប់ កាត់បន្ថយ គម្លាត

## វិបត្តិ ?

រវាង អ្នកក្រនិងអ្នកមាន នៅក្នុង ស្មារតី នៃ សមភាព នៃ ភ័ព្វ របស់មនុស្សម្នាក់ៗ។ ដូច្នេះ រដ្ឋ មាន បេសកកម្ម ជា កាតព្វកិច្ច ក្នុង ក្របខណ្ឌ នៃនយោបាយ នៃ មនុស្សជាតិ ប្រុងប្រជា ដល់ អ្នកក្រ គ្រប់មធ្យោបាយ ដើម្បីឲ អ្នកក្រ អាច មាន លទ្ធភាព ចូលទៅ ទីកន្លែងទុរគម[3] ទាំងពួង ស្មើភាពនឹងអស់គេ សំរាប់ កសាងជីវិត របស់ខ្លួន។

លើសអំពី បញ្ហា នៃ មាគ៌ា នៃ វាសនាជីវិត បើយើង ត្រឡប់ទៅ ក្នុង អតីតកាល យើងមើលឃើញថា ការផ្សងព្រេងដ៏អស្ចារ្យ នៃ បុព្វបុរស នៃ មនុស្សលោក ធ្វើអោយផុសចេញ នូវ វប្បធម៌ នៃ មនុស្សជាតិ ដូចយ៉ាង ការបង្កើត នៃ ភាសា, សហគមតូចៗ, នគរ និង មហានគរ មានរដ្ឋ, កសិកម្ម, ទីក្រុង, សាសនា, វិចិត្រសិល្បៈ, វិមានស្ដឹមស្ដៃ, សង្គ្រាម, ទាសករ, អត្តង្គត, អភិសូន្យ[4], ការកញ្ជ្រោល ដ៏សំបើម ឆ្លួត ពុខ្ជរខ្ជាយ និង គ្រោធពិរោធ នៃ ប្រវត្តិសាស្ត្រ, ការលូតលាស់ នៃបច្ចេកទេស នៃពាណិជ្ជវិស័យ, ក្រុមហ៊ុននៃសមុទ្រ ច្បាំងដណ្ដើម ដែនសមុទ្រ, សង្គ្រាមពិភពលោក, អំពើ សម្លាប់ប្រជាករ និង លោកូបនីយកម្ម សព្វថ្ងៃ។ បើយើងរំពឹងថា ដំណាក់ការនិមួយៗ នៃ ការវិវត្តិ នៃ មនុស្សជាតិ វាមាន សភាព ជាសត្វចៀម ធ្វើតាម តែគេបង្គាប់ ក្នុង ការិយកម្ម ដដែលៗ នៅក្នុង វដ្ដសង្សារ, បើទុកជា មិនបំភ្លេច

---

[3] ទីកន្លែងទុរគម ; lieu d'accès difficile.

[4] អភិសូន្យ ; anéantissement.

ថា កូនក្មេង មុននឹងទៅជា មនុស្សពេញវ័យ នៅក្រោម ឱវាទមាតាបិតា វា មាន ចំណង់ ពុះខ្ជោលក្នុងចិត្ត នៃ ការផ្សងព្រេង ដែលជា ចំណង់ ហួសពី អ្វី ដែល អាចមើលឃើញ និង អាចគិតស្មានបាន ដូចយ៉ាង មហាបុព្វបុរសធំៗ ក្នុងសកលលោក បានធ្វើអោយការផ្សងព្រេងរបស់ខ្លួន អាច ប្តូរ ចរន្ត នៃប្រវត្តិសាស្ត្រ ហើយ នាំ មនុស្សជាតិ ដើរតាម ចំណង់ចិត្តអស្ចារ្យនោះ។ យើងអាច ចោទជាសំនួរថា តើ ការផ្សងព្រេង នៃអនាគត វា អន់ជាង ពីអតីតកាល ? តែបើយើង យក ដំណើរ អស្ចារ្យ នៃ មនុស្សជាតិ ក្នុងដំណាក់ការនិមួយៗ មកគិត គឺ យើង ច្បាស់ជាឆ្លើយដាច់ខាតថា ការផ្សងព្រេង នៃអនាគត គឺច្បាស់ជា មាន ភាពសំបើមដូចគ្នានឹង អតីតកាល។ តែ អ្វីដែលយើងមិនទាន់ដឹងវា នាំចោទជាសំនួរថា តើ ការផ្សងព្រេងដ៏អស្ចារ្យ នៃអនាគតរបស់មនុស្សជាតិ វានាំមក នូវ អ្វីអស្ចារ្យ ជាថ្មី តាមទស្សនៈ៖ លទ្ធភាព នៃ ចំណេះចេះដឹង, បច្ចេកទេស, ការទំនាក់ទំនង នៃ នរវិទ្យាលោកធាតុវិទ្យា[5], ធម្មជាតិ នៃ មនុស្សជាតិ។ តើ ការផ្សងព្រេងដ៏អស្ចារ្យ ជាថ្មី វា ជា ដំណោះស្រាយ នៃវិបត្តិសង្គមបច្ចុប្បន្ន ឬ វាគ្រាន់តែជាថ្នាំសំរាប់បន្ថយការឈឺចាប់ របស់អ្នកមានជម្ងឺ ទូរាទូរន្ត ឬ មហារីក តែប៉ុណ្ណោះ ?

នៅត្រង់ចំណុចនេះឯង ខ្មែរ អ្នកសុទិដ្ឋិនិយម តាំងពីបុរាណកាលមក មានជំនឿថា ការផ្សងព្រេងដ៏អស្ចារ្យ នៅសម័យ

[5] ការទំនាក់ទំនង នៃនរវិទ្យាលោកធាតុវិទ្យា ; relation anthropocosmique.

## វិបត្តិ ?

មហានគរខ្មែរ វានឹងមានកើតឡើងជាថ្មី សំរាប់ដោះស្រាយ វិបត្តិជាតិខ្មែរសព្វថ្ងៃ ដែលជាគំនិត នាំបង្កើតបាន នូវ ប្រជាជំនឿមួយ គឺ ការយាងមកដល់ស្រុកខ្មែរ នៃ ព្រះបាទ ធម្មិក ពីទេវលោក មកជួយរំដោះប្រជាពលរដ្ឋ។ អបិយជំនឿនេះ វាអាចជា ដំណោះស្រាយ និង ជា វិបត្តិផង។ ចំណុច នៃ ដំណោះស្រាយ គឺ សេចក្តីសង្ឃឹម ចិញ្ចឹមនៅក្នុងចិត្តជានិច្ច ថា វិបត្តិខ្មែរ នឹងមាន អ្នកសង្គ្រោះជាតិ មានបារមី អាចនឹងដោះស្រាយបាន។ តែ វា ក៏ជា អត្តវិបត្តិ បន្ថែមលើវិបត្តិ ព្រោះ វាជា សេចក្តីសង្ឃឹម អកម្ម ដេករង់ចាំតែប៉ុណ្ណោះ។ ចំណែក ការយក សម័យមហានគរ មកធ្វើជាយោគ សំរាប់ធ្វើជាគោលចំណង់ នៃការគស៊ូរជាតិ វាជា ការអំពាវនាវ ឃ្លាតឆ្ងាយពី ចិត្តគំនិតខ្មែរ សព្វថ្ងៃច្រើនណាស់ ហើយជា និមិត្តរូប អរូបិយ ផង សំរាប់ យុវជន ដែលមិនសូវយកចិត្តទុកដាក់ អំពី ប្រវត្តិសាស្ត្រជាតិខ្លួនឯង។

ដូច្នេះ ការកំណែទំរង់ នូវ ចិត្តគំនិត វាជា អាទិភាព ចាំបាច់ សំរាប់ដោះស្រាយ វិបត្តិខ្មែរ ព្រោះវាជាផ្លូវ នាំមក នូវ ចំណង រវាងខ្មែរនឹងខ្មែរ ក្នុង ស្មារតី សាមគ្គីជាតិ និង សតិសម្បជញ្ញៈ នាំបង្កើត សម្បទា (aptitude) ដើម្បី យល់ដឹង និង ក្តាប់បាន នូវ បញ្ហា ទាំងអស់ ដែល ជា សេចក្តីត្រូវការ របស់ គំនិត នៃ ការកំណែទំរង់៕